ប្រទេសចិន-ខេត្តយូណាន

云南日报报业集团
YUNNAN DAILY PRESS GROUP

១២

ព័ត៌មានសង្ខេប | លេខ ៥២ ថ្ងៃ ព្រហស្បតិ៍ ទី ៣១ ខែ តុលា ឆ្នាំ ២០២៤

澜湄传媒 Mekong News Network
云南省南亚东南亚区域国际传播中心
Yunnan Intl Communication Center for South and Southeast Asia

ដើរកម្សាន្តនៅយូណាន ទៅទស្សនានៅអង្គរ

ដោយ ÷ លីហ្ស កល្យាណ ឌាំងហ្ស

"ផ្លូវសូត្រលើអាកាស" មិត្តភាពយូរអង្វែង

នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៣ អាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ ត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការ។ ចាប់តាំងពីបើកដំណើរការផ្លូវអាកាសចរណ៍អស់រយៈពេលមួយឆ្នាំកន្លងទៅនេះ បណ្តាញផ្លូវអាកាសចរណ៍រវាងចិន និងកម្ពុជាកាន់តែជិតស្និទ្ធ ដោយសម្រេចបាន "ការតភ្ជាប់រឹង" នៃហេដ្ឋារចនាសម្ព័ន្ធ "ការតភ្ជាប់ទន់" នៃច្បាប់និងស្តង់ដារ និងជំរុញ "ការតភ្ជាប់ពីបេះដូង" នៃការផ្លាស់ប្តូររវាងប្រជាជន និងប្រជាជន។ លើកនេះ សូមយើងធ្វើដំណើរតាមលោកបណ្ឌិត ជា មុនីឫទ្ធិ សមាជិកគណៈកម្មាធិការប្រតិបត្តិនៃសមាគមមិត្តភាពកម្ពុជា-ចិន និងជាប្រធានសមាគមអភិវឌ្ឍន៍ទំនាក់ទំនងកម្ពុជា-ចិន ហើយទទួលចំណាប់អារម្មណ៍នៃសេចក្តីស្រឡាញ់ និងមិត្តភាពដែលបានមកពី "ផ្លូវសូត្រលើអាកាស" នេះ។

មិត្តភាពដែលរត់រកគ្នា

នៅក្នុងសាលទទួលភ្ញៀវនៃអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ រូបសំណាកព្រហ្ម មុខបួនពណ៌មាសចាំងពន្លឺក្រោមរស្មីព្រះអាទិត្យ ហើយស្វាគមន៍ភ្ញៀវទេសចរគ្រប់រូបដោយស្នាមញញឹមដ៏ក់ក្តៅ។ ចាប់តាំងពីការបើកឱ្យដំណើរការចរាចរណ៍ផ្លូវអាកាសកាលពីខែតុលា ឆ្នាំមុន អាកាសយានដ្ឋានទំនើបនេះបានដំណើរការយ៉ាងរលូនក្នុងរយៈពេលមួយឆ្នាំ ដោយបានតភ្ជាប់ទីក្រុងចំនួន ១៥ ក្នុងប្រទេសចំនួន ៨។ ក្នុងចំណោមនោះ ជើងហោះហើរត្រង់ "គុនមីង-សៀមរាប" ដែលដំណើរការដោយក្រុមហ៊ុន China Eastern Airlines Yunnan Co., Ltd. បានក្លាយជាទំនាក់ទំនងដ៏សំខាន់រវាងប្រទេសចិន និងកម្ពុជា។

នៅថ្ងៃមួយនៃរដូវស្លឹកឈើជ្រុះដ៏ស្រស់បំព្រង លោកបណ្ឌិត ជា មុនីឫទ្ធិ បានមកដល់ក្រុមហ៊ុនអាកាសយានដ្ឋានយូណាន គ្រុប ហើយបានជួបបុគ្គលិកពីរនាក់របស់ក្រុមហ៊ុនគឺ លោកស្រី ម៉ាវ ស៊ុនជាវ និង លោក ឡៃ ឆីង ហើយបានស្តាប់ពួកគេនិយាយរៀបរ៉ាប់អំពីគម្រោងនិមិត្តរូបនៃការរួមស្ថាបនា "ខ្សែក្រវាត់ និងផ្លូវ" រវាងប្រទេសចិន និងកម្ពុជា គឺរឿងរ៉ាវនៅពីក្រោយអាកាសយានដ្ឋានអន្តរជាតិអង្គរ។

លោកស្រី ម៉ាវ ស៊ុនជាវ គឺជាបុគ្គលិកផ្នែកទីផ្សារនៃក្រុមហ៊ុនអាកាសយានដ្ឋានយូណាន គ្រុប ធ្លាប់បានធ្វើការនៅខេត្តសៀមរាបអស់រយៈពេលមួយឆ្នាំកន្លះ ដោយបានជួយរៀបចំការបើកដំណើរការព្រលានយន្តហោះអន្តរជាតិ សៀមរាបអង្គរ។ "នេះគឺជារូបថតនៃការចំណាយពេលដ៏ស្រស់បំព្រងរួមគ្នាជាមួយមិត្តភក្តិក្នុងតំបន់ បន្ទាប់ពីចេញពីធ្វើការ ពួកយើងបានញ៉ាំសាច់អាំង និងផឹកស្រាបៀរជាមួយគ្នា..." លោកស្រី ម៉ាវ ស៊ុនជាវ បើកអាល់ប៊ុមរូបថតនៅក្នុងទូរស័ព្ទដៃហើយចែករំលែកអនុស្សាវរីយ៍ដ៏មានតម្លៃជាមួយលោកបណ្ឌិត ជា មុនីឫទ្ធិ។ ក្នុងអំឡុងពេលនោះ នាងបានរៀនភាសាខ្មែរ ព្រមទាំងបង្កើតមិត្តភាពយ៉ាងរឹងមាំជាមួយសហការីជនជាតិខ្មែរ។ បច្ចុប្បន្ននេះ មានបុគ្គលិកជនជាតិចិនជាង ៣0 នាក់ ដែលប្រចាំធ្វើការក្នុងប្រទេសកម្ពុជាអស់រយៈពេលជាយូរ ហើយបានធ្វើការ និងរស់នៅជាមួយសហការីក្នុងតំបន់។

លោក ឡៃ ឆីង ជានាយករងនៃនាយកដ្ឋានគ្រប់គ្រងប្រតិបត្តិការនៃក្រុមហ៊ុនសេវាកម្មផ្ទាល់ដីអាកាសយានយូណាន បានចូលរួមក្នុងការងាររៀបចំមុនពេលបើកដំណើរការអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ ហើយទទួលបន្ទុកបង្កើតប្រព័ន្ធសេវាកម្មផ្ទាល់ដី និងបណ្តុះបណ្តាលបុគ្គលិកក្នុងតំបន់។ "អ្វីដែលខ្ញុំនឹករលឹកបំផុតគឺមិត្តភក្តិជនជាតិខ្មែរទាំងឡាយដែលប្រៀបដូចជាក្រុមគ្រួសារ ពួកយើងនៅតែរក្សាទំនាក់ទំនងជិតស្និទ្ធបន្ទាប់ពីខ្ញុំត្រឡប់មកប្រទេសចិនវិញ"។ លោកបានប្រាប់លោកបណ្ឌិត ជា មុនីឫទ្ធិ ថា ដោយមានជំនួយពីសហសេវិកកម្ពុជា សហសេវិកចិនបានរស់នៅ និងធ្វើការប្រកបដោយផាសុកភាព ហើយបង្កើនការយល់ដឹង និងមិត្តភាពនៅទីនេះ។

ដំណើរនៃការរស់ឡើងវិញ

"លោកពូ ទីក្រុងគុនមីងនៅឯណា? តើពួកយើងត្រូវជិះយន្តហោះយូរប៉ុណ្ណាទើបដល់ទីនោះ"? ក្នុងដំណើរនៃជើងហោះហើរ China Eastern Airlines ដែលមានជើងហោះហើរលេខ MU9610 ពីភ្នំពេញទៅកាន់ទីក្រុងគុនមីង កុមារកម្ពុជា ឈ្មោះ ស្រី ណូឡា អាយុ ៩ ឆ្នាំ ដែលមានជំងឺបេះដូងពីកំណើតមានចម្ងល់ ហើយសួរទៅកាន់លោកបណ្ឌិត ជា មុនីឫទ្ធិ កែវភ្នែករបស់នាងពោរពេញទៅដោយការរំពឹងទុក។

ក្នុងនាមជាមន្ត្រីកម្ពុជាទទួលបន្ទុកគម្រោង "ដំណើរក្តីស្រឡាញ់" លោកបណ្ឌិត ជា មុនីឫទ្ធិ បានអមដំណើរកុមារកម្ពុជាដែលមានជំងឺបេះដូងពីកំណើតទៅទីក្រុងគុនមីងដើម្បីព្យាបាលជាច្រើនលើកមកហើយ សម្រាប់ពួកគេ នេះគឺជាដំណើរនៃការរស់ឡើងវិញ។ ចាប់តាំងពីខែមករា ឆ្នាំ ២០១៨មក គម្រោងនេះបានពិនិត្យកុមារជាង ៧ ម៉ឺននាក់នៅក្នុងប្រទេសកម្ពុជា ព្រមទាំងបានផ្តល់ការព្យាបាលដោយឥតគិតថ្លៃដល់កុមារដែលមានជំងឺបេះដូងពីកំណើតជិត ១00 នាក់។

បន្ទាប់ពីយន្តហោះចុះចតនៅទីក្រុងគុនមីង ស្រី ណូឡា និងឪពុករបស់នាងបានដើរចេញពីកាប៊ីនដែលមានការអមដំណើរដោយលោក-បណ្ឌិត ជា មុនីឫទ្ធិ។ ក្នុងអំឡុងពេលធ្វើដំណើរ ពួកគេមានអារម្មណ៍ថា ទទួលបានការយកចិត្ត-ទុកដាក់ និងផ្តល់សេវាកម្មយ៉ាងល្អពីអ្នកបម្រើការលើយន្តហោះនៃក្រុមហ៊ុនអាកាសចរណ៍ China Eastern Airlines Yunnan ហើយភាពតានតឹងក្នុងចិត្តរបស់ពួកគេបានរលាយបាត់បន្តិចម្តងៗ។ អ្នកបម្រើការលើយន្តហោះរបស់ក្រុមហ៊ុនអាកាសចរណ៍ China Eastern Airlines បានទទួលការបណ្តុះបណ្តាលពិសេសជាភាសាខ្មែរ។

ក្រុមហ៊ុនអាកាសចរណ៍ China Eastern Airlines Yunnan ដំណើរការជើងហោះហើរត្រង់ពីទីក្រុងគុនមីងទៅភ្នំពេញ និងពីទីក្រុងគុនមីងទៅខេត្តសៀមរាប ដើម្បីបំពេញតម្រូវការរបស់អ្នកដំណើរឱ្យកាន់តែប្រសើរឡើង ចាប់ពីខែមេសា ឆ្នាំនេះ ជើងហោះហើរពីទីក្រុងគុនមីងទៅភ្នំពេញ បានបង្កើនដល់ជើងហោះហើរចំនួនមួយជារៀងរាល់ថ្ងៃ ហើយជើងហោះហើរទៅសៀមរាបត្រូវបានបង្កើនដល់ជើងហោះហើរចំនួន ៣ ជើងក្នុងមួយសប្តាហ៍។

ផ្កាវីកដែលមិនចេះស្រពោន



នៅមជ្ឈមណ្ឌលនវានុវត្តន៍បច្ចេកវិទ្យាផ្កាអន្តរជាតិ ស្ថិតនៅផ្លូវតូរ៉ាណាន ខណ្ឌឆ្លងកុង ទីក្រុងគុនមីង លោកស្រី ធាន មីន អ្នកស្រាវជ្រាវរងនៅវិទ្យាស្ថានស្រាវជ្រាវផ្កានៃបណ្ឌិត្យសភាវិទ្យាសាស្ត្រកសិកម្មខេត្តយូណាន បានណែនាំដល់លោកបណ្ឌិត ជា មុនីឫទ្ធិ ឆ្ងាយពីផ្កាកុលាបដែលដាំដុះដោយប្រើប្រាស់បច្ចេកវិទ្យាដាំដុះគ្មានដី ដូចជា Nightingale, Quicksand, Pride, Ice Pink ជាដើម ផ្កាកុលាបទាំងនេះត្រូវចំណាយពេលតែ ៣ ខែប៉ុណ្ណោះពីការដាំដល់ការប្រមូលផល។ លោកស្រី ធាន មីន រំពឹងថា ការអនុវត្តការផ្លាស់ប្តូរ និងកិច្ចសហប្រតិបត្តិការស៊ីជម្រៅបន្ថែមទៀតជាមួយស្ថាប័នពាក់ព័ន្ធនៅកម្ពុជានឹងនាំយកបច្ចេកវិទ្យា និងបទពិសោធន៍ដាំផ្កាបន្ថែមទៀតមកកាន់ប្រទេសកម្ពុជា។

លោក ហ្ស៊ូ ឆាវ អគ្គនាយកក្រុមហ៊ុន Kunming Dianwang Flower Co., Ltd. បានចែករំលែកពីអាជីវកម្មផ្ការបស់ក្រុមហ៊ុននៅប្រទេសកម្ពុជា។ ចាប់តាំងពីផ្កាស្រស់ត្រូវបាននាំចេញពីទីក្រុងគុនមីងមកប្រទេសកម្ពុជាក្នុងឆ្នាំ២០១៤ ទំហំនៃការនាំចេញបានកើនឡើងពី ៣00 តោន ដល់ជាង ១ ៥00 តោននៅឆ្នាំនេះ។ ដោយសារការបើកដំណើរការ និងការពង្រីកផ្លូវអាកាសនៅអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ អាជីវកម្មផ្កាស្រស់របស់លោក ហ្ស៊ូ ឆាវ កាន់តែរីកចម្រើនក្នុងប្រទេសកម្ពុជា។

"ពួកយើងមិនត្រឹមតែលក់ផ្កានៅប្រទេសកម្ពុជាប៉ុណ្ណោះទេ យើងក៏ដាំផ្កានៅប្រទេសកម្ពុជាផងដែរ"។ លោក ហ្ស៊ូ ឆាវ បានបង្កើតក្រុមហ៊ុនរួមទុននៅក្នុងទីក្រុងភ្នំពេញ និងបានសហការជាមួយវិទ្យាស្ថានស្រាវជ្រាវផ្កានៃបណ្ឌិត្យសភាវិទ្យាសាស្ត្រកសិកម្មខេត្តយូណាន ហើយបានបង្កើតមជ្ឈមណ្ឌលរងនៃមជ្ឈមណ្ឌលអភិវឌ្ឍន៍ចំពោះប្រទេសអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ក្នុងប្រទេសកម្ពុជា ដើម្បីលើកកម្ពស់ការបណ្តុះ-បណ្តាលបច្ចេកទេសដាំដំណាំក្នុងតំបន់ និងការសាងសង់មូលដ្ឋានដាំដំណាំរួម។

"អ្នកទាំងអស់គ្នាមិនត្រឹមតែនាំផ្កាស្រស់ពីខេត្តយូណានមកប្រទេសកម្ពុជាប៉ុណ្ណោះទេ ថែមទាំងធ្វើឱ្យផ្កាស្រស់ទាំងនេះចាក់ឫស និងរីកដុះដាលក្នុងប្រទេសកម្ពុជា ផ្កាវីកមិនចេះស្រពោន ពិតជាអស្ចារ្យណាស់"! លោកបណ្ឌិត ជា មុនីឫទ្ធិ និយាយដោយសប្បាយរីករាយ॥

អ្នកនិពន្ធភាសាចិន ÷ RAN XIULAN អ្នកនិពន្ធភាសាខ្មែរ ÷ LI ZHA SHEN YAN រចនារូបភាព ÷ SUN YONGGANG